

MEKONG RIVER COMMISSION
FOR SUSTAINABLE DEVELOPMENT

# ការប្ដេជ្ញាចិត្តអំពី ការបញ្ជ្រាបយេនឌ័រទៅក្នុងការអភិវឌ្ឍធនធានទឹក នៅអាងទន្លេមេគង្គក្រោម

## កម្ពុជា - ឡាវ - ថៃ - វៀតណាម
## សំរាប់ការអភិវឌ្ឍដោយនិរន្តរភាព

# គោលនយោបាយ និងយុទ្ធសាស្ត្រយេនឌ័រ



នៅគណៈកម្មការទន្លេមេគង្គ ការសម្រេចបានតុល្យភាពរវាងទិដ្ឋភាពនៃការអភិវឌ្ឍសេដ្ឋកិច្ច សង្គម និងបរិស្ថាន កាន់តែមានសារៈសំខាន់ឡើងៗ ។ ការពិចារណាអំពីទិដ្ឋភាពផ្នែកសង្គម ត្រូវបានកំណត់ថា ជាគោលដៅមួយក្នុងចំណោមគោលដៅយុទ្ធសាស្ត្រសំខាន់ៗទាំងឡាយ ដែលបង្កើតជាមូលដ្ឋានគោលនៃទស្សនៈវិស័យរបស់គណៈកម្មការទន្លេមេគង្គសម្រាប់អាងទន្លេមួយដែលប្រកបដោយវិបុលភាពផ្នែកសេដ្ឋកិច្ច យុត្តិធម៌សង្គម និងប្រកបដោយបរិស្ថានល្អ។ ការពិចារណាអំពីទិដ្ឋភាពផ្នែកសង្គមជាចំណុចដែលត្រូវគិតគូរអោយបានដិតដល់ក្នុងការសម្រេចអោយបាននូវគោលដៅអភិវឌ្ឍន៍ និងការធ្វើផែនការប្រើប្រាស់ធនធានធម្មជាតិ។ ក្នុងចំណោមការពិចារណាទាំងអស់ យេនឌ័រ គឺជាបញ្ហាអាទិភាពដែលត្រូវតែគិតគូរ។ សម្រាប់ប្រទេសដែលជាសមាជិកគណៈកម្មការទន្លេមេគង្គ យេនឌ័រ គឺជាបញ្ហាអាទិភាពមួយនៃអាទិភាពជាតិទាំងឡាយ ដើម្បីបង្កើតសមធម៌សេដ្ឋកិច្ច និងផលប្រយោជន៍សង្គម សំរាប់សកម្មភាពអភិវឌ្ឍន៍។ យេនឌ័រត្រូវបានគេរាប់ចូលថាជាកត្តាអថេរផ្នែកសេដ្ឋកិច្ច និង សង្គមដ៏ចម្បងមួយដែលមានសារជាតិប្រទាក់ក្រឡាជាមួយនឹងវិស័យផ្សេងៗទៀត ហើយដែលចាំបាច់ត្រូវគិតគូរដោយយកចិត្តទុកដាក់នៅក្នុងរាល់ទិដ្ឋភាពទាំងអស់នៃកម្មវិធីអភិវឌ្ឍន៍របស់គណៈកម្មការទន្លេមេគង្គ។

ក្នុងន័យនេះ គោលនយោបាយ និងយុទ្ធសាស្ត្រយេនឌ័ររបស់គណៈកម្មការទន្លេមេគង្គ ត្រូវបានបង្កើតក្នុងឆ្នាំ ១៩៩៨ និង អនុម័តនៅឆ្នាំ ២០០០ ដោយប្រទេសជាសមាជិកតាមរយៈក្រុមប្រឹក្សាគណៈកម្មការទន្លេមេគង្គ។

# គោលនយោបាយយេនឌ័ររបស់ គណៈកម្មការទន្លេមេគង្គ

ការគ្រប់គ្រងធនធានទឹកចម្រុះប្រកបដោយជោគជ័យ ត្រូវការវិធីដោះស្រាយប្រទាក់ក្រឡាគ្នាគ្រប់វិស័យ សំរាប់ការធ្វើផែនការសំរាប់ការអភិវឌ្ឍ ការប្រើប្រាស់ និងសំរាប់ការការពារធនធានទឹក ។ វិធីសាស្ត្រដោះស្រាយបែបចម្រុះនេះភ្ជាប់ទិដ្ឋភាពស្ថាប័ន ទិដ្ឋភាពគ្រប់គ្រង ទិដ្ឋភាពសង្គម ទិដ្ឋភាពយេនឌ័រ និង ទិដ្ឋភាពសេដ្ឋកិច្ចជាមួយនឹងការវិភាគបច្ចេកទេស និងការដោះស្រាយបញ្ហា។ វិធីសាស្ត្រភ្ជាប់ទិដ្ឋភាពដែលទាក់ទងគ្នានេះផ្តល់ឱកាសសម្រាប់ការអភិវឌ្ឍមួយដែលឆ្លើយតបនឹងតម្រូវការខុសៗគ្នារបស់ស្ត្រី និងបុរសដោយឈរលើមូលដ្ឋានស្មើភាពគ្នា ។

ដោយផ្អែកលើយុទ្ធសាស្ត្រយេនឌ័រនេះ គោលបំណងនៃគោលនយោបាយយេនឌ័រ គឺដើម្បីកំណត់វិធីដោះស្រាយចំបងរបស់គណៈកម្មការទន្លេមេគង្គ លើបញ្ហាយេនឌ័រក្នុងការអភិវឌ្ឍធនធានទឹក និងធនធានពាក់ព័ន្ធ នៅក្នុងអាងទន្លេមេគង្គ ។ ■

## សនិទានភាពសំរាប់ គោលនយោបាយយេនឌ័ររបស់ គណៈកម្មការទន្លេមេគង្គ



# វិសាលភាព

គណៈកម្មការទន្លេមេគង្គយកចិត្តទុកដាក់ជាសំខាន់ទៅលើយេនឌ័រ ជាជាងយកចិត្តទុកដាក់ទៅលើស្ត្រី ។ យេនឌ័រសំដៅទៅលើតួនាទី ភារកិច្ច តម្រូវការ ចំណង់ចំណូលចិត្ត និងសមត្ថភាពរបស់បុរស និងស្ត្រី ។ កត្តាទាំងអស់នេះទទួលរងឥទ្ធិពលពីកត្តាសង្គម និងវប្បធម៌ ។ ហេតុដូច្នេះ ពាក្យថាយេនឌ័រមិនមានន័យដូចពាក្យ "ភេទ" ទេ ខណៈដែលពាក្យភេទសំដៅតែទៅលើភាពខុសគ្នាផ្នែកជីវៈរូប (ឧ. ប្រដាប់ភេទ) តែប៉ុណ្ណោះ ។ នៅក្នុងបរិបទទន្លេមេគង្គ កិច្ចសហប្រតិបត្តិការនៅក្នុងក្របខ័ណ្ឌចម្រុះរបស់គណៈកម្មការទន្លេមេគង្គ មានគោលដៅសម្រេចអោយបាននូវការអភិវឌ្ឍចម្រុះទៅលើធនធានទឹក និងធនធានពាក់ព័ន្ធនៅអាងទន្លេមេគង្គពេញលេញមួយប្រកបដោយនិរន្តរភាព ដើម្បីធ្វើអោយគុណភាពជីវិតរបស់ប្រជាជនបានប្រសើរឡើង។ បុរស និងស្ត្រី តែងដើរតួនាទីខុសគ្នានៅក្នុងការអភិវឌ្ឍ ហេតុដូច្នេះក៏មានតម្រូវការ ចំណង់ចំណូលចិត្ត ការទទួលបាន និងការគ្រប់គ្រងធនធានខុសគ្នាៗដែរ ។

ចាំបាច់ត្រូវមានទស្សនៈយេនឌ័រមួយ ដើម្បីធានាអោយបានថាតម្រូវការជាក់ច្បាស់របស់បុរស-ស្ត្រី ភាពងាយរងគ្រោះ និងសមត្ថភាពត្រូវបានគេទទួលស្គាល់ និងដោះស្រាយអោយបានត្រឹមត្រូវ ។



## គោលដៅ

គោលដៅជារួមរបស់គោលនយោបាយនេះ គឺត្រូវបញ្ជ្រាបយេនឌ័រទៅក្នុងកិច្ចខិតខំប្រឹងប្រែងអភិវឌ្ឍន៍របស់គណៈកម្មការទន្លេមេគង្គ ដើម្បីធានាអោយបានថា គ្រប់កម្មវិធីអភិវឌ្ឍន៍របស់គណៈកម្មការទន្លេមេគង្គ ផ្តល់ផលប្រយោជន៍ដល់បុរស និងស្ត្រី ស្មើៗគ្នាអោយស្របទៅនឹងតម្រូវការខុសៗគ្នា និងស្របតាមការចែករំលែក និងការចូលរួមស្មើៗគ្នារបស់បុរសស្ត្រីនៅគ្រប់កម្រិត ។

## គោលការណ៍ណែនាំ

១ សមធម៌យេនឌ័រ និងសមភាពយេនឌ័រ ត្រូវបានចាត់ទុកជាផ្នែកមួយនៃគ្រប់សកម្មភាពការងារនៃកម្មវិធី និងគម្រោងទាំងអស់របស់គណៈកម្មការទន្លេមេគង្គ ។

២ ប្រសិទ្ធភាព និងភាពសក្តិសិទ្ធិ ក្នុងការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ តម្រូវអោយមានការទទួលស្គាល់ថា រាល់សកម្មភាពរបស់គណៈកម្មការទន្លេមេគង្គ មានឥទ្ធិពលខុសៗគ្នា ទៅលើស្ត្រី និងបុរស ហើយទទួលស្គាល់ថា ទស្សនៈ តម្រូវការ ចំណង់ចំណូលចិត្ត តួនាទី និងធនធានផ្សេងៗគ្នា គួរតែត្រូវបានគេយកចិត្តទុកដាក់នៅគ្រប់កម្រិត ។

៣ សមធម៌ និងសមភាពយេនឌ័រ គឺជាគុណតម្លៃជាមូលដ្ឋានដែលត្រូវពង្រឹងបន្ថែម និងត្រូវបញ្ចូលនៅក្នុងជម្រើសនៃការអភិវឌ្ឍ និងការងារជាក់ស្តែងរបស់ស្ថាប័ន ។

## យុទ្ធសាស្ត្រ និងសកម្មភាព ដើម្បីជួយគាំទ្រដល់ការសម្រេចបានគោលនយោបាយយេនឌ័រ

ការអនុម័តលើយុទ្ធសាស្ត្រយេនឌ័រដោយប្រទេសជាសមាជិកទាំងបួន នាឆ្នាំ ១៩៩៨ បានពង្រឹងការប្តេជ្ញាចិត្តរបស់គណៈកម្មការទន្លេមេគង្គ ក្នុងនាមជាអង្គការគ្រប់គ្រង និងអភិវឌ្ឍអាងទន្លេ និង ក្នុងនាមជាអ្នកសម្របសម្រួលដើម្បីឈានទៅសម្រេចបាននូវគោលនយោបាយយេនឌ័រ ។



**ដើម្បីសម្រេចគោលដៅនេះ  គណៈកម្មការទន្លេមេគង្គនឹងៈ**

១. ធានាអោយបាននូវឱកាសស្មើគ្នាក្នុងចំណោមបុគ្គលិកជាស្ត្រី និងបុរសនៅក្នុងការជ្រើសរើសបុគ្គលិក នៅក្នុងការជំរុញទឹកចិត្តនៅក្នុងការផ្តល់ឯកសិទ្ធិ ការបណ្តុះបណ្តាល និងនៅក្នុងល័ក្ខខ័ណ្ឌការងារ ។

២. ខិតខំប្រឹងប្រែងធ្វើអោយមានទិន្នន័យញែកតាមភេទ ប្រយោជន៍សម្រាប់ការវាយតម្លៃតម្រូវការ និង ការធ្វើផែនការកម្មវិធី ហើយនិងដើម្បីបញ្ចូលការវិភាគយេនឌ័រទៅក្នុងការរៀបចំកម្មវិធី ការអនុវត្ត ការត្រួតពិនិត្យ និងវាយតម្លៃកម្មវិធី ។

៣. បង្កើនការយល់ដឹង និងជំនាញរបស់បុគ្គលិក និងជំនាញមន្ត្រីនៃក្រសួង-ស្ថាប័នពាក់ព័ន្ធ ដើម្បីអោយពួកគេអាចសិក្សាពីភាពខុសគ្នាក្នុងសង្គម រវាងស្ត្រី និងបុរសនៅពេលធ្វើការរៀបចំ នៅពេលអនុវត្ត ត្រួតពិនិត្យ និងវាយតម្លៃកម្មវិធី ។

៤. ធ្វើការពិនិត្យឡើងវិញជាប្រព័ន្ធ និងដាក់អោយដំណើរការនូវនីតិវិធីស្ថាប័នដែលធានាបានថា រាល់សេចក្តីត្រូវការរបស់ក្មេងស្រី ក្មេងប្រុស និងរបស់ស្ត្រី និងបុរសត្រូវបានគេបំពេញដោយសមធម៌ នៅពេលដែលគេធ្វើផែនការសកម្មភាពអភិវឌ្ឍន៍របស់គណៈកម្មការទន្លេមេគង្គ ។

# យុទ្ធសាស្ត្រយេនឌ័ររបស់គណៈកម្មការទន្លេមេគង្គ

យុទ្ធសាស្ត្រយេនឌ័ររបស់គណៈកម្មការទន្លេមេគង្គត្រូវបានបង្កើតឡើងដើម្បីលើកតំកើង និងដាក់បញ្ចូលទស្សនៈយេនឌ័រទៅក្នុងគោលការណែនាំគោលនយោបាយ ផែនការកម្មវិធី និងគម្រោងនានារបស់គណៈកម្មការទន្លេមេគង្គ។ ដើម្បីសំរេចគោលដៅនេះ គោលនយោបាយអង្គការត្រូវបានបង្កើតឡើងដើម្បីដាក់បញ្ចូលបញ្ហាយេនឌ័រទៅក្នុងសកម្មភាពការងារអភិវឌ្ឍន៍ដែលទាក់ទងនឹងធនធានទឹក និងធនធានពាក់ពន្ធ័ដទៃទៀត។ លើសពីនេះទៅទៀត គណៈកម្មការទន្លេមេគង្គកំពុងតែលើកកម្ពស់ការកសាងសមត្ថភាពតាមរយៈការចែកចាយឧបករណ៍ដែលផ្តល់ការគាំទ្រ ខាងការគ្រប់គ្រងលើការអនុវត្តគោលនយោបាយទាំងនេះ។



## (សមាសភាគចំបង)

១ ការបង្កើតគោលនយោបាយបញ្ជ្រាបយេនឌ័រ

២ ទទួលបានការប្តេជ្ញាចិត្ត និងការគាំទ្រពីមន្ត្រី និងអ្នកគ្រប់គ្រងថ្នាក់ខ្ពស់របស់គណៈកម្មការទន្លេមេគង្គ

៣ បង្កើនការយល់ដឹងអំពីយេនឌ័រនៅក្នុងអង្គការ

៤ ការកសាងសមត្ថភាពខាងយេនឌ័រ និងការអភិវឌ្ឍ

៥ បង្កើតរចនាសម្ព័ន្ធអង្គការ និងនីតិវិធីដែលឆ្លើយតបទៅនឹងយេនឌ័រ

៦ ការផ្តល់ឧបករណ៍ចាំបាច់សំរាប់ការអនុវត្តសកម្មភាពអភិវឌ្ឍន៍ដែលឆ្លើយតបទៅនឹងយេនឌ័រ



## ការបង្កើតគោលនយោបាយបញ្ជ្រាបយេនឌ័រ

១

សមាសភាគទីមួយសំដៅលើការបង្កើតឡើងនូវគោលនយោបាយយេនឌ័រ សំរាប់គណៈកម្មការទន្លេមេគង្គ។ សមាសភាគនេះ គប្បីធ្វើការសំរបសំរួលនៅក្នុងការកំណត់សារជាថ្មីនូវនិយមន័យ គោលដៅការអភិវឌ្ឍ ការរៀបចំ និងដំណើរការស្ថាប័ន ដើម្បីឆ្លុះបញ្ចាំងអំពីទស្សនៈ និងអាទិភាពរបស់ស្ត្រី និងរបស់បុរស។ សមាសភាគនេះ គប្បីចូលរួមចំណែក ដល់ការកាត់បន្ថយភាពខុសគ្នាខាងយេនឌ័រនៅក្នុងកិច្ចខិតខំប្រឹងប្រែងអភិវឌ្ឍន៍ ប្រយោជន៍ដើម្បីឈានទៅការប្រើប្រាស់ធនធានទឹក និងធនធានដទៃទៀត ប្រកបដោយនិរន្តរភាព ។

## ការប្តេជ្ញាចិត្តពីគណៈកម្មការទន្លេមេគង្គ

២

សមាសភាគទីពីរ នៃយុទ្ធសាស្ត្រយេនឌ័រ រួមមានកិច្ចប្រឹងប្រែងដើម្បីទទួលបានការប្តេជ្ញាចិត្ត និងការគាំទ្រពីមន្ត្រី និងអ្នកគ្រប់គ្រងថ្នាក់ខ្ពស់របស់គណៈកម្មការទន្លេមេគង្គ ។ សមាសភាគនេះនឹងត្រូវសំរេចអោយបានតាមរយៈការរៀបចំព្រឹត្តិការណ៍បញ្ជ្រាបយេនឌ័រដល់សមាជិកក្រុមប្រឹក្សា សមាជិកគណៈកម្មធិការរួមរបស់គណៈកម្មការទន្លេមេគង្គ និងមន្ត្រីជាន់ខ្ពស់នៃលេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ ក៏ដូចជាដល់អ្នកធ្វើសេចក្តីសំរេចចិត្តពាក់ព័ន្ធនឹងធនធានទឹក នៅតាមស្ថាប័ននានានៃបណ្តាប្រទេសតាមដងមេគង្គ។

## ការបង្កើតការយល់ដឹងអំពីយេនឌ័រនៅក្នុងអង្គការ

៣

ដើម្បីអោយមានការផ្លាស់ប្តូរជាបណ្តើរៗក្នុងវប្បធម៌នៃអង្គការ វគ្គបណ្តុះបណ្តាល ឬក៏ព្រឹត្តិការណ៍ដទៃទៀតស្តីអំពីការបញ្ជ្រាបយេនឌ័រនឹងត្រូវរៀបចំឡើងសំរាប់បុគ្គលិកគ្រប់កំរិតទាំងអស់នៅក្នុងស្ថាប័នពាក់ពន្ធ័ នៅគណៈកម្មាធិការជាតិទន្លេមេគង្គ និងលេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ។

## ការកសាងសមត្ថភាព ខាងយេនឌ័រ និង ការអភិវឌ្ឍ

៤

ការកសាងសមត្ថភាពខាងយេនឌ័រ និងការអភិវឌ្ឍ គឺជាផ្នែកសំខាន់មួយទៀតរបស់យុទ្ធសាស្ត្រយេនឌ័រ ។ ការកសាងសមត្ថភាព មានរួមបញ្ចូលទាំងការរៀបចំវគ្គបណ្តុះបណ្តាលនានា ស្តីអំពីកាធ្វើផែនការយេនឌ័រ និងការវិភាគយេនឌ័រសំរាប់មន្ត្រីគំរោងរបស់គណៈកម្មការទន្លេមេគង្គ និងមន្ត្រីគំរោងរបស់ស្ថាប័នពាក់ពន្ធ័ ព្រមទាំងសំរាប់ បុគ្គលិកតាមខេត្ត ។ ការកសាងសមត្ថភាព ក៏មានការសំរបសំរួល បណ្តាគំរោងសាកល្បងដែលគេអនុវត្តនៅតាមស្ថាប័នពាក់ពន្ធ័មួយចំនួន ដើម្បីធ្វើការបណ្តុះបណ្តាលមន្ត្រីគំរោងអោយចេះវិភាគយេនឌ័រ នៅកំរិតអនុវត្តជាក់ស្តែង។ ការសាងសមត្ថភាព ក៏មានជាលក្ខណៈសំរបសំរួលការអប់រំថ្នាក់អនុបណ្ឌិតផ្នែកស្រាវជ្រាវយេនឌ័រ និងការបណ្តុះបណ្តាលខាងយេនឌ័រ សំរាប់មន្ត្រីសំខាន់ៗរបស់ប្រទេសនៅតាមដងទន្លេមេគង្គ។

## អង្គការដែលឆ្លើយតបទៅនឹងយេនឌ័រ

៥

សមាសភាគទីប្រាំនៃយុទ្ធសាស្ត្រយេនឌ័ររបស់គណៈកម្មការទន្លេមេគង្គ គឺការបញ្ជ្រាបយេនឌ័រ ទៅក្នុងរចនាសម្ព័ន្ធ និងនីតិវិធីនានា របស់អង្គការដែលឆ្លើយតបទៅនឹងយេនឌ័រ ។ សមាសភាគនេះ រួមមានការបង្កើតឡើងនូវគណៈកម្មាធិការប្រតិបត្តិមួយនៅលេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ និងប្រសិនបើចាំបាច់ត្រូវបង្កើត ក្រុមបង្គោលខាងយេនឌ័នៅតាមស្ថាប័នពាក់ព័ន្ធនៃប្រទេសតាមដងទន្លេ ។ ជាងនេះទៅទៀតសមាសភាគទីប្រាំ សំដៅធានាអោយបានថាសមាជិកម្នាក់ៗនៃគណៈកម្មធិការប្រតិបត្តិ ឬក្រុមបង្គោលចូលរួមក្នុងអង្គការចាត់តាំងសំខាន់ៗដែលជាអ្នកធ្វើសេចក្តីសំរេចចិត្ត។ សមាសភាគទីប្រាំនេះក៏កំណត់ថានឹងរៀបចំសៀវភៅណែនាំការគ្រប់គ្រងគំរោង និងគោលការណែនាំគំរោងដទៃទៀតអោយមានលក្ខណៈឆ្លើយតបនឹងយេនឌ័រ ។ ជាចុងក្រោយការបង្កើតនូវមូលដ្ឋានទិន្នន័យសំរាប់កម្មវិធី និងគំរោងរបស់លេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ និងស្ថាប័នពាក់ព័ន្ធ គួរតែអាចផ្តល់ទិន្នន័យញែកភេទសំរាប់ការបណ្តុះបណ្តាលដល់មន្ត្រីដែលទទួលបន្ទុកខាងយេនឌ័រ។

## ឧបករណ៍យេនឌ័រ

## ៦

សមាសភាគចុងក្រោយនៃយុទ្ធសាស្ត្រនេះ គឺការផ្តល់នូវឧបករណ៍ចាំបាច់មួយសំរាប់ការអនុវត្តកម្មវិធីអភិវឌ្ឍន៍ ដែលឆ្លើយតបនឹងយេនឌ័រ ។ សមាសភាគនេះ រួមមានការបោះពុម្ព និងការផ្សព្វផ្សាយជាភាសាជាតិនូវ “គោលការណ៍ណែនាំស្តីអំពីការបញ្ជ្រាបយេនឌ័រនៅក្នុងការអភិវឌ្ឍធនធានទឹកនៅអាងទន្លេមេគង្គក្រោម” ក៏ដូចជាការផលិតឡើងវិញនិងការចែកចាយនូវកូនសៀវភៅអំពីការបញ្ជ្រាបយេនឌ័រ ដែលនឹងភ្ជាប់មកជាមួយនូវបញ្ជីផ្ទៀងផ្ទាត់ជាក់ស្តែងមួយ ។

ការអនុវត្តសមាសភាគនៃយុទ្ធសាស្ត្រទាំងនេះ នឹងរួមចំណែកដល់ការសំរេចបាននូវតុល្យភាពដ៏ត្រឹមត្រូវមួយសំរាប់ទិដ្ឋភាពទាំង៣នៃការអភិវឌ្ឍប្រកបដោយនិរន្តរភាពនៅអាងទន្លេមេគង្គ ។ ទិដ្ឋភាពទាំង៣នោះ គឺទិដ្ឋភាពសេដ្ឋកិច្ច ទិដ្ឋភាពបរិស្ថាន និងទិដ្ឋភាពសង្គមនៃការអភិវឌ្ឍសំរាប់ប្រយោជន៍មនុស្សជំនាន់ក្រោយ ។






# គណៈកម្មការទន្លេមេគង្គ

កម្ពុជា - ឡាវ - ថៃ - វៀតណាម

www.mrcmekong.org

ការិយាល័យលេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គនៅវៀងច័ន្ទ

ការិយាល័យប្រធានលេខាធិការដ្ឋាន   គណៈកម្មការទន្លេមេគង្គ

អាគារលេខ   ១៨៤   ផ្លូវ   ហ្វា   ងុម

ប្រអប់សំបុត្រលេខ   ៦១០១   ទីក្រុងវៀងច័ន្ទ   សាធារណៈរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ

ទូរស័ព្ទលេខ:   ៨៥៦-២១   ២៦៣   ២៦៣

ទូរសារលេខ:   ៨៥៦-២១   ២៦៣   ២៦៤